





## តើមូលនិធិ Schmitz ជាអ្វី ?

មូលនិធិនេះត្រូវបានបង្កើតឡើងនៅប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស ដោយ Werner Peter Schmitz-Hille ជាមូលនិធិឯករាជ្យ ស្របច្បាប់ និងមិនស្វែងរកប្រាក់ចំណេញ ។
មូលនិធិ Schmitz ទាំងពីរធ្វើសកម្មភាពដើម្បីប្រយុទ្ធប្រឆាំងនឹងភាពខ្វះខាត និងភាពក្រីក្រនៅក្នុងចំណោមប្រជាជនក្រីក្រជាងគេនៅក្នុងពិភពលោករបស់យើង អស់រយៈពេលជាងម្ភៃឆ្នាំមកហើយ ។

គោលដៅចម្បងរបស់មូលនិធិ Schmitz គឺផ្តល់ការគាំទ្រដល់គម្រោងជួយខ្លួនឯងក្នុងមូលដ្ឋាន ក្នុងវិស័យផលិតអាហារទ្រទ្រង់ជីវិត អាជីវកម្មដោយដៃ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបង្កើនកម្រិតចំណូល ។
ដូចគម្រោងអភិវឌ្ឍន៏សហប្រតិបត្តិការនានាដែរ យើងខ្ញុំក៏បានចូលរួមផងដែរក្នុងការងារមនុស្សធម៌ និងគម្រោងខ្នាតតូចផ្នែកលើកកម្ពស់ការយល់ដឹងល្អប្រសើរជាងមុនរវាងប្រជាជាតិ ។

ជួយដើម្បីអោយជួយខ្លួនឯង

គំនិតស្នូលនៅពីក្រោយគម្រោងរបស់យើងខ្ញុំទាំងអស់ គឺជួយដើម្បីអោយជួយខ្លួនឯង។ យើងខ្ញុំមានគោលដៅពង្រឹងការជឿទុកចិត្តលើខ្លួនឯងរបស់អ្នកដែលយើងខ្ញុំព្យាយាមជួយ និងគាំទ្រដល់ពួកគេក្នុងការខិតខំប្រឹងប្រែងរបស់ពួកគេ ដើម្បីស្វែងរកផ្លូវចាកចេញពីភាពក្រីក្រដោយខ្លួនពួកគេផ្ទាល់ ។

## តើយើងខ្ញុំផ្តល់ការគាំទ្រដល់ប្រជាជន និងគម្រោងប្រភេទអ្វីខ្លះ ?

ការគាំទ្រផ្តល់ដោយមូលនិធិ Schmitz ផ្តោតគោលដៅជាចម្បងទៅលើគម្រោងខ្នាតតូចនានា ដែលមានគោលបំណងកែលម្អដោយផ្ទាល់នូវស្ថានភាពកសិកម្ម សង្គម និងអេកូឡូស៊ីអោយកាន់តែប្រសើរឡើង នៅក្នុងចំណោមក្រុមប្រជាជនក្រីក្រ និងប្រជាជនបាត់បង់ឱកាស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏ ។ យើងខ្ញុំផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើកុមារអនាថា យុវជនដែលសង្គមផាត់ចោល ជនពិការកាយសម្បទា គ្រួសារក្រីក្រ និងមនុស្សចាស់ជរា ។

គម្រោងដែលយើងផ្តល់ការគាំទ្រ កំណត់ទិសដៅច្បាស់លាស់ដែលត្រូវអនុវត្ត នៅក្នុងរយៈពេលកំណត់ជាក់លាក់មួយ ដោយមានការចូលរួមជាអតិបរមាពីថ្នាក់មូលដ្ឋាន ។

ជាមួយនឹងដំណើរការរបស់គម្រោង គោលបំណងរបស់យើងគឺថាប្រជាជនក្នុងមូលដ្ឋានដែលបានចូលរួម គួរមានការទទួលខុសត្រូវកាន់តែច្រើនឡើង ។ ប្រការនេះបង្កើននូវកម្រិតនៃការជឿទុកចិត្តលើខ្លួនឯងរបស់ពួកគេ
និងផ្តល់ដល់ពួកគេនូវចំណេះដឹង ដើម្បីបន្តការកែលម្អដែលគម្រោងបាននាំមក
ក្រោយពីហិរញ្ញប្បទានបានបញ្ចប់ ក្រោម ការប្រឹងប្រែងផ្ទាល់របស់ពួកគេ ។

ប្រសិទ្ធភាព

## តើមូលនិធិ Schmitz ធ្វើសកម្មភាពនៅប្រទេសណាខ្លះ ?

មូលនិធិ Schmitz ប្រមូលផ្តុំសកម្មភាពរបស់ខ្លួនផ្តោតទៅលើតំបន់មួយចំនួនតូច ដើម្បីអាចទាញផលប្រយោជន៏ពីសកម្មភាពរួមគ្នា និងសម្រេចគោលដៅដែលបានកំណត់ជាអតិបរមា និងប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ពួកគេប្រកបដោយប្រសិទ្ធភាព ។ ខាងក្រោមនេះជាប្រទេសដែលយើងខ្ញុំផ្តល់ការគាំទ្រ :

- **អាស៊ីអាគ្នេយ៏**
  ឥណ្ឌូនេស៊ី កម្ពុជា ឡាវ
  ហ្វីលីពីន ស្រីលង្កា វៀតណាម
- **អាមេរិកខាងត្បូង និងកណ្តាល**
  បូលីវី អេក្វាឌ័រ នីការ៉ាគ័រ ពេរូ
- **អឺរ៉ុបខាងកើត**
  ម៉ុលដាវី រ៉ូម៉ានី សហព័ន្ធរុស្ស៊ី

និរន្តរភាព

មូលនិធិ Schmitz ចូលរួមនៅក្នុងគម្រោងផ្តល់ជំនួយ ដោយសហប្រតិបត្តិការជាមួយអង្គការផ្តល់ជំនួយ និងមិនស្វែងរកប្រាក់ចំណេញដទៃទៀតដែលមានគោលដៅប្រហាក់ប្រហែល ឬផ្តល់ការគាំទ្រដោយផ្ទាល់ដល់អង្គការ ស្ថាប័ន និងក្រុមជួយខ្លួនឯងក្នុងមូលដ្ឋាន ។

## តើ Werner Peter Schmitz-Hille ជាអ្នកណា ?



ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះចំណាប់អារម្មណ៍របស់លោកអ្នកមកលើមូលនិធិរបស់ខ្ញុំ ។ ពាក្យស្លោកប្រចាំជីវិតរបស់ខ្ញុំគឺ : "មនុស្សធមិចាប់ផ្តើមនៅ ផ្ទះ" ។ ទុកអោយយើងខ្ញុំធ្វើសកម្មភាព និងស្វែងរកផ្លូវជាមួយគ្នា !

ខ្ញុំកើតនៅឆ្នាំ១៩១៤ ដោយមានសុខភាពល្អ ខ្ញុំអាចរីករាយ និងរំលឹកឡើងវិញអំពីជីវិតដែលបានអូសបន្លាយជិតមួយសវត្សរ៍ ។
ខ្ញុំបានបង្កើតមូលនិធិរបស់ខ្ញុំ ដើម្បីផ្តល់ជំនួយដោយផ្ទាល់ដល់ប្រជាជនដែលជួបប្រទះការលំបាក ។ បញ្ហាសំខាន់ចំពោះខ្ញុំគឺថា យើងកាត់បន្ថយសេចក្តីលំបាកវេទនា និងភាពក្រីក្រ ហើយនៅក្នុងដំណើរការនេះ ផ្តល់ការគាំទ្រដល់ប្រជាជនក្រីក្រ ផ្តល់ដល់ពួកគេនូវក្តីសង្ឃឹម សេក្តីក្លាហាន ដើម្បីប្រឈមមុខនឹងអនាគត ព្រមទាំងទស្សនវិស័យសម្រាប់ពួកគេផ្ទាល់ និងគ្រួសាររបស់ពួកគេ ។

ខ្ញុំមានការព្រួយបារម្ភជាពិសេសអំពីជនក្រីក្រ និងជនដែលសង្គមផាត់ចោល ។ ខ្ញុំគិត គួរដល់ជនពិការដែលគេបំភ្លេចចោល មនុស្សចាស់ជរា និងមនុស្សមានជំងឺ កុមារ កំព្រា ជនជាតិភាគតិចដែលបាត់បង់សិទ្ធិស្របច្បាប់របស់ខ្លួន និងប្រជាជនបាត់បង់ ឱកាសផ្សេងទៀត ។ បទពិសោធន៏បង្ហាញអោយឃើញថា ការជួយដើម្បីអោយជួយ ខ្លួនឯងពិតប្រាកដ ជារឿយៗ
គឺជាទម្រង់ល្អបំផុតនៃការជួយដែលយើងអាចផ្តល់បាន ។

ជាការពិត យើងមិនអាចជួយមនុស្សទាំងអស់នៅគ្រប់ទីកន្លែងបានទេ ។ ប៉ុន្តែ ប្រសិនបើ យើងរួមគ្នា យើងអាចព្យាយាមជួយដល់មនុស្សបានច្រើនបំផុតតាមដែល អាចធ្វើទៅបាន ។

ពី Werner Peter Schmitz-Hille

ស្លាបទឹករបស់យើងខ្ញុំ

## តើអាចធ្វើពាក្យសុំហិរញ្ញប្បទានយ៉ាងដូចម្តេច ?

លោកអ្នកអាចដាក់ពាក្យសុំហិរញ្ញប្បទានពីមូលនិធិ Schmitz នៅគ្រប់ពេលទាំងអស់ ។ គ្មានកាលបរិច្ឆេទពិសេសសម្រាប់ការដាក់ពាក្យសុំ ឬរយៈពេលរង់ចាំនោះទេ ។
ពាក្យសុំបង្កើតគម្រោងអាចធ្វើឡើងនៅលើពាក្យសុំ ដែលបានរៀបចំរួចជាពិសេសដែលអាចដោនឡូតចេញពីវែបសាយត៍របស់មូលនិធិ ។ សូមបំពេញពាក្យសុំ និងផ្ញើមកការិយាល័យយើងខ្ញុំ យកល្អ ផ្ញើតាមអ៊ីមែលសម្រាប់ការវាយតម្លៃដំបូង ។ ពាក្យសុំគួរសរសេរជាភាសាអាល្លឺម៉ង់ ឬអង់គ្លេស ។

យើងរីករាយចំពោះការគាំទ្ររបស់លោកអ្នកចំពោះការងាររបស់មូលនិធិ Schmitz ។ មូលនិធិ Schmitz នៅប្រទេសអាល្លឺងម៉ង និងមូលនិធិ Schmitz-Hille នៅប្រទេសស្វីសទាំងពីរត្រូវបានទទួលស្គាល់ជាផ្លូវការថាជាអង្គការមនុស្សធមិ ។ ទៅតាមសំណើ យើងខ្ញុំនឹងរីករាយផ្តល់ដល់ម្ចាស់ជំនួយនូវការបញ្ជាក់អំពីអំណោយរបស់ពួកគេ សម្រាប់គោលបំណងផ្នែកពន្ធដារ ។

**គណនីធនាគារសម្រាប់អំណោយ :**

| | |
|---|---|
| ប្រទេសអាល្លឺម៉ង់ | ធនាគារ Deutsche |
| | លេខកូដ Sort : ៣០០ ៧០០ ១០ |
| | លេខគណនី : ១៣ ០៧ ៤៩៥ |
| ប្រទេសស្វីស | ឥណទានស្វីស |
| | លេខគណនី : ៨៤០២២៩-៥១ |


**ទំនាក់ទំនង**

អាសយដ្ឋានប្រៃសណីយ

W. P. Schmitz-Stiftung
Info@Schmitz-Stiftung.de

Schmitz-Hille-Stiftung
Info@Schmitz-Hille-Stiftung.org

Volmerswerther Str. 86
40221 Düsseldorf

ទូរស័ព្ទ : +៤៩ ២១១ ៣៩៨៣៧៧០
ទូរសារ : +៤៩ ២១១ ៣៩៨៣៧៨២


ពាក្យសុំ



W. P. Schmitz-Stiftung

Schmitz-Hille-Stiftung

www.Schmitz-Stiftung.de
www.Schmitz-Hille-Stiftung.org

ព័ត៌មានទូទៅ